# ព្រះរាជក្រម

## ស្តីពី

## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង
## រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល
## នៃសហព័ន្ធស្វីស ស្តីពីការជំរុញ និងការការពារវិនិយោគ

ជស/រកម/០៧៩៩/០៤

## យើង

## ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើជាផ្លូវការនូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្ម មាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី៨ ដល់ជំពូកទី១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពីសម្តេចនាយករដ្ឋមន្ត្រី និងអំពីទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ប្រកាសអោយប្រើ

ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសហព័ន្ធស្វិស ស្តីពីការជំរុញ និងការការពារវិនិយោគ ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ១៩៩៩ នាសម័យប្រជុំរដ្ឋសភា លើកទី២ នីតិកាលទី២ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាម លើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុង នៅថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ នាសម័យ ប្រជុំពេញ អង្គលើកទី១ នីតិកាលទី១ ហើយដែលមាន សេចក្តីទាំងស្រុងដូចតទៅ :

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់
# ស្ដីពី
# ការអនុម័តយល់ព្រម
# លើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាល
# នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល
# នៃសហព័ន្ធស្វីស ស្ដីពីការជំរុញ
# និងការការពារវិនិយោគ

# ច្បាប់

# ស្តីពី

# ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសហព័ន្ធស្វីស ស្តីពីការជំរុញ និងការការពារវិនិយោគ

**មាត្រា ១ :**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធស្វីស ស្តីពីការជំរុញ និងការការពារវិនិយោគ ដែលធ្វើនៅភ្នំពេញ នាថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៦ ហើយដែលមានអត្ថបទ ទាំងស្រុងភ្ជាប់មកជាមួយ ។

**មាត្រា ២ :**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

រាជធានីភ្នំពេញថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៩
ក្នុងព្រះបរមនាម និងតាមព្រះរាជបង្គាប់
**ប្រមុខរដ្ឋ ស្តីទី**
**ហត្ថលេខា**
**ជា ស៊ីម**

បានបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
**ហត្ថលេខា**
**គាត ឈន់**

លេខ : ១៦០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ហត្ថលេខា និងត្រា**
**ឃុន ជិនកេន**

# កិច្ចព្រមព្រៀង

# រវាង

# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

# និង

# សហព័ន្ធស្វីស

# ស្តីពីការជំរុញ និងការការពារវិនិយោគ

# បុព្វកថា

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រុមប្រឹក្សាភិបាលនៃសហពន្ធ័ស្វ៊ីស

ដោយមានគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ដើម្បីជាប្រយោជន៍ទៅវិញទៅមករបស់ប្រទេសទាំងពីរ

ដោយមានគោលបំណងបង្កើតឡើង និងថែរក្សាលក្ខខ័ណ្ឌអនុគ្រោះសំរាប់ដំណើរការវិនិយោគដែលធ្វើឡើងដោយវិនិយោគិនទាំងឡាយនៃភាគីកិច្ចសន្យាមួយ នៅក្នុងទឹកដីនៃភាគីកិច្ចសន្យាមួយទៀត

ដោយទទួលស្គាល់នូវសេចក្តីត្រូវការ ដើម្បីជំរុញនិងការពារវិនិយោគក្រៅប្រទេសទាំងឡាយ ក្នុងទិសដៅបង្កើននូវវឌ្ឍនភាពសេដ្ឋកិច្ចរបស់ប្រទេសទាំងពីរ

ភាគីកិច្ចសន្យាទាំងពីរបានព្រមព្រៀងគ្នាដូចតទៅ៖

## មាត្រា ១

## និយមន័យ

ក្នុងគោលបំណងនៃកិច្ចព្រមព្រៀងនេះ :

១- ពាក្យ "វិនិយោគិន" ក្នុងលក្ខខណ្ឌនៃភាគីកិច្ចសន្យាទាំងសងខាងគឺសំដៅទៅលើ÷

ក- រូបវន្តបុគ្គល ដែលជាជនជាតិនៃភាគីកិច្ចសន្យាណាមួយ ស្របតាមច្បាប់របស់ភាគីកិច្ចសន្យានោះ ។

ខ- និតិបុគ្គលទាំងឡាយដែលត្រូវបានតែងតាំង ឬរៀបចំតាមច្បាប់របស់ភាគីកិច្ចសន្យាណាមួយ ហើយជាប់ពាក់ព័ន្ធក្នុងដំណើរការពាណិជ្ជកម្មដ៏សំខាន់ក្នុងទឹកដីនៃភាគីកិច្ចសន្យានោះ ។

គ- និតិបុគ្គលដែលត្រូវបានបង្កើតឡើង ក្រៅពីច្បាប់របស់ភាគីកិច្ចសន្យានោះ÷

១. ដែលមានផលប្រយោជន៍លើសពី ៥០ភាគរយឡើងទៅជាកម្មសិទ្ធិរបស់រូបវន្តបុគ្គល ឬ និតិបុគ្គលរបស់ភាគីកិច្ចសន្យានោះ ឬក៏

២. មានលក្ខណៈពាក់ព័ន្ធទៅនឹងរូបវន្តបុគ្គល ឬ និតិបុគ្គលនៃភាគីកិច្ចសន្យានោះ ដែលមានអំណាចតែងតាំងសមាជិកក្រុមប្រឹក្សាភិបាលភាគច្រើន ឬដោយឡែក ដឹកនាំការងារដោយស្របច្បាប់ ។

២- ពាក្យ "វិនិយោគ" មានន័យថា ទ្រព្យសម្បត្តិគ្រប់ប្រភេទ ដោយរួមទាំង :

ក- ចលនៈទ្រព្យ អចលនៈទ្រព្យ និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ដូចជា ទសភាគ ការបញ្ចាំ ការទារប្រាក់ពីកូនបំណុល ការសន្យា និងផលុបភោគផ្សេងៗ ។

ខ- ភាគហ៊ុន ហ៊ុន ឬការចូលរួមតាមលក្ខណៈផ្សេងទៀតក្នុងក្រុមហ៊ុន ។

គ- សិទ្ធិទាមទារប្រាក់ ឬ ការងារដទៃទៀតដែលមានតម្លៃជាទឹកប្រាក់តាមលក្ខខណ្ឌនៃកិច្ចសន្យា ។

ឃ- ការរក្សាសិទ្ធិចំលង សិទ្ធិលើទ្រព្យសម្បត្តិឧស្សាហកម្ម (ដូចជាប្រកាសនិយបត្រ គក្កកម្មគំរូនៃការប្រើប្រាស់គំនូរ ឬគំរូឧស្សាហកម្ម ពាណិជ្ជ ឬសេវាសញ្ញា នាមពាណិជ្ជ ការបញ្ជាក់ដើមកំណើតទំនិញ) ចំណេះធ្វើ និងកេរ្តិ៍ឈ្មោះជំនួញ ។

ង- សម្បទានតាមច្បាប់សាធារណៈ ដោយរួមទាំងសម្បទានសំរាប់ការស្រាវជ្រាវ និស្សារណកម្ម ឬការធ្វើអាជីវកម្មលើធនធានធម្មជាតិព្រមទាំងសិទ្ធិផ្សេងទៀតដែលច្បាប់ផ្តល់អោយ ដោយការចុះកិច្ចព្រមព្រៀង ឬដោយការសំរេចរបស់អាជ្ញាធរ ដោយស្របទៅតាមច្បាប់ ។

៣- ពាក្យ " ប្រាក់ចំណូល " មានន័យថា ចំនួនទឹកប្រាក់ដែលបានផលពីការធ្វើវិនិយោគ ជាពិសេស មាន រួមទាំងប្រាក់ចំណេញ ការប្រាក់ កំណើនដើមទុន ប្រាក់ចំណេញតាមហ៊ុន ចំណូលពីការលក់សិទ្ធិ និង ថ្លៃឈ្នួលផ្សេងៗ ។

៤- ពាក្យ " ទឹកដី " រាប់បញ្ចូលទាំងដែនសមុទ្រដែលស្ថិតនៅជាប់នឹងឆ្នេរនៃប្រទេសពាក់ព័ន្ធ ដែលក្នុងនោះ ប្រទេសនោះមានសិទ្ធិ និងយុត្តាធិការក្នុងការគ្រប់គ្រង ស្របតាមច្បាប់អន្តរជាតិ ។

## មាត្រាទី ២
## វិសាលភាពនៃការអនុវត្តន៍កិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះដំណើរការវិនិយោគទាំងឡាយនៅក្នុងទឹកដីនៃភាគីកិច្ចសន្យាណាមួយ ដែលត្រូវបានបង្កើតឡើង ដោយអនុលោមទៅតាមច្បាប់ និងបទបញ្ញត្តិនានានៃទឹកដីរបស់ភាគីនោះ និង ដែលត្រូវធ្វើឡើងដោយវិនិយោគិននៃភាគីកិច្ចសន្យាមួយទៀត ទោះបីនៅមុនពេល ឬក្រោយពេលដែលកិច្ច ព្រមព្រៀងនេះបានចូលជាធរមាន ។

## មាត្រាទី ៣
## ការអនុញ្ញាត

១- នៅក្នុងទឹកដីរបស់ខ្លួន ភាគីកិច្ចសន្យានីមួយៗត្រូវជំរុញអោយអស់លទ្ធភាពដល់ដំណើរការវិនិយោគទាំង ឡាយ ដែលវិនិយោគិននៃភាគីកិច្ចសន្យាមួយទៀតបានបង្កើតឡើង ព្រមទាំងត្រូវអនុញ្ញាតិអោយមាន ការវិនិយោគបែបនោះ ស្របតាមច្បាប់និងបញ្ញាតិរបស់ខ្លួន ។

២- នៅពេលដែលភាគីកិច្ចសន្យាមួយ អនុញ្ញាតិអោយភាគីកិច្ចសន្យាមួយទៀតធ្វើវិនិយោគនៅលើទឹកដី របស់ខ្លួន ភាគីនោះត្រូវតែផ្តល់នូវការអនុញ្ញាតិដ៏សំខាន់ៗដែលពាក់ព័ន្ធទៅនឹងសកម្មភាពវិនិយោគនោះ ព្រមទាំងអនុវត្តកិច្ចព្រមព្រៀងផ្តល់អាជ្ញាប័ណ្ណ និងកិច្ចសន្យាផ្សេងៗចំពោះជំនួយខាងបច្ចេកទេស ពាណិជ្ជកម្ម និងរដ្ឋបាល ។ ភាគីកិច្ចសន្យានីមួយៗត្រូវតែខិតខំប្រឹងប្រែងផ្តល់នូវការអនុញ្ញាតិនានា ដែលចាំបាច់ ដែលពាក់ព័ន្ធនៅនឹងសកម្មភាពរបស់ទីប្រឹក្សានិងបុគ្គលិកបរទេសដែលមានសមត្ថភាព ។

## មាត្រាទី ៤
## ប្រព្រឹត្តកិច្ចនៃការវិនិយោគ

១- នៅគ្រប់ពេលវេលាទាំងអស់ ដំណើរការវិនិយោគនិងចំណូលរបស់វិនិយោគិននៃភាគីកិច្ចសន្យានីមួយៗ ត្រូវបានផ្តល់នូវប្រព្រឹត្តកិច្ចដ៏យុត្តិធម៌និងស្មើភាពគ្នា ហើយត្រូវទទួលនូវការការពារ និងសន្តិសុខដ៏ពេញលេញ ក្នុងទឹកដីនៃភាគីនៃកិច្ចសន្យាមួយទៀត ។ គ្មានភាគីកិច្ចសន្យាណាមួយអាចប៉ះពាល់ ដោយវិធានការមិនសមហេតុផលឬរើសអើងដល់ការគ្រប់គ្រង ការថែរក្សា ការប្រើប្រាស់ ការបន្ត ឬការបោះបង់វិនិយោគនោះឡើយ ។

២- ក្នុងទឹកដីរបស់ខ្លួន ភាគីកិច្ចសន្យានីមួយៗត្រូវតែយល់ព្រមផ្តល់នូវប្រព្រឹត្តិកិច្ចផលវិនិយោគ ឬចំណូលរបស់វិនិយោគិននៃភាគីកិច្ចសន្យាមួយទៀត ដោយលក្ខណៈអនុគ្រោះ ដែលមិនតិចជាងអ្វីដែលត្រូវផ្តល់ចំពោះវិនិយោគ ឬចំណូលរបស់វិនិយោគិនរបស់ខ្លួន ឬ ចំពោះវិនិយោគ និងចំណូលរបស់វិនិយោគិននៃប្រទេសទីបីណាមួយ ប្រសិនបើប្រព្រឹត្តកិច្ចណាមួយមានលក្ខណៈប្រសើរជាង ។

៣- នៅក្នុងទឹកដីរបស់ខ្លួន ភាគីកិច្ចសន្យានីមួយៗត្រូវផ្តល់ប្រព្រឹត្តិកិច្ចផលវិនិយោគិននៃភាគីកិច្ចសន្យាមួយទៀត លើការគ្រប់គ្រង ការប្រើប្រាស់ ការទទួល ឬការចែកចាយវិនិយោគរបស់គេ ដែលមានលក្ខណៈអនុគ្រោះមិនតិចជាងអ្វីដែលខ្លួនផ្តល់ផលវិនិយោគិនរបស់ខ្លួនផ្ទាល់ ឬវិនិយោគិនរបស់ភាគីនៃប្រទេសទីបីណាមួយ ប្រសិនបើប្រព្រឹត្តិកិច្ចនេះមានលក្ខណៈអនុគ្រោះច្រើនចំពោះវិនិយោគិន ដែលពាក់ពន្ធ័ ។

៤- ប្រសិនបើភាគីកិច្ចសន្យាណា ផ្តល់នូវអត្ថប្រយោជន៍ពិសេសចំពោះវិនិយោគិននៃប្រទេសទីបីណាមួយ ដោយផ្អែកលើកិច្ចព្រមព្រៀងដែលបង្កើតឡើងសំរាប់តំបន់ពាណិជ្ជកម្មសេរី សហគមន៍គយ ឬ ទីផ្សាររួម ឬ ដោយផ្អែកលើកិច្ចព្រមព្រៀងសំរាប់ជៀសវាងការយកពន្ធជាន់គ្នា ភាគីកិច្ចសន្យានោះនឹងមិនចាំបាច់ផ្តល់នូវអត្ថប្រយោជន៍ទាំងនោះដល់វិនិយោគិនទាំងឡាយនៃភាគីមួយទៀតឡើយ ។

## មាត្រាទី ៥
## ការផ្ទេរដោយសេរី

១- ភាគីកិច្ចសន្យានីមួយៗ ត្រូវផ្តល់សិទ្ធិដល់វិនិយោគិននៃភាគីកិច្ចសន្យាមួយទៀត ដែលដំណើរការវិនិយោគនៅក្នុងទឹកដីរបស់ខ្លួន ក្នុងការផ្ទេរដោយសេរីនូវចំនួនទឹកប្រាក់ ដែលពាក់ព័ន្ធទៅនឹងដំណើរការវិនិយោគទាំងនោះ ជាពិសេស÷

ក)- ប្រាក់ចំណូល

ខ)- សំណងចំពោះបំណុលដែលមានចុះកិច្ចព្រមព្រៀង ឬ ចំនួនទឹកប្រាក់ដើម្បីដោះស្រាយភាតព្វកិច្ចនៃកិច្ចសន្យាផ្សេងទៀត

គ)- ប្រាក់ចំណូលពីការលក់មួយផ្នែកឬជាសរុប ឬពីការជំរះបញ្ជីវិនិយោគ ព្រមទាំងការបង្កើនទុនបន្ថែមផង ។

២- ក្នុងកាលៈទេសៈដែលតុល្យភាពជញ្ជីងទូទាត់ជួបការលំបាក ភាគីកិច្ចសន្យាមានសិទ្ធិកំណត់ការផ្ទេរដែលបានបញ្ជាក់ក្នុងកថាខ័ណ្ឌ (១) ចំណុច (គ) នៃមាត្រានេះ ។ ក្នុងករណីនេះ ការផ្ទេរនឹងបានអនុញ្ញាតិអោយធ្វើជាពីរដំណាក់កាលក្នុងមួយឆ្នាំ ។

## មាត្រាទី ៦
## ការរឹបអូស និងសំណង

១- គ្មានភាគីកិច្ចសន្យាណាមួយ អាចចាត់វិធានការដោយផ្ទាល់ ឬដោយប្រយោល ដើម្បីរឹបអូស ធ្វើជាតូបនីយកម្ម ឬចាត់វិធានការដទៃផ្សេងទៀតដែលមានលក្ខណៈ ឬឥទ្ធិពលដូចគ្នានឹងវិធានការទាំងនោះ នៅលើដំណើរការវិនិយោគរបស់វិនិយោគិននៃភាគីកិច្ចសន្យាផ្សេងទៀតឡើយ លើកលែងតែវិធានការនោះធ្វើឡើងដើម្បីជាផលប្រយោជន៍សាធារណៈ លើមូលដ្ឋាននៃការមិនរើសអើង ហើយត្រូវធ្វើតាមនីតិវិធីដ៏ត្រឹមត្រូវ និងត្រូវបង្កើតឡើងនូវលក្ខខណ្ឌនានា ដើម្បីធានាអោយមានសំណងយ៉ាងគ្រប់គ្រាន់និងមានប្រសិទ្ធភាពចំពោះការរឹបអូសនោះ ។ សំណងនោះត្រូវមានចំនួនទឹកប្រាក់ស្របតាមតម្លៃទីផ្សារនៃវិនិយោគ នៅមុនពេលភ្លាមៗដែលការរឹបអូសត្រូវបានអនុវត្ត ឬដែលត្រូវបានគេដឹងជាសាធារណៈ អាស្រ័យទៅតាមករណីណាមួយដែលបានកើតមុនគេ ។ ចំនួននៃសំណង រួមទាំងការប្រាក់ នឹងត្រូវទូទាត់ជារូបិយប័ណ្ណរបស់ប្រទេសម្ចាស់ដើមវិនិយោគ ហើយត្រូវទូទាត់ដោយគ្មានការពន្យារពេល ចំពោះបុគ្គលដែលមានសិទ្ធិទទួល ដោយមិនគិតអំពីអាស័យដ្ឋាន ឬទីលំនៅឡើយ ។

៦- វិនិយោគិននៃភាគីកិច្ចសន្យាមួយ ដែលការវិនិយោគរបស់ខ្លួនបានទទួលរងគ្រោះ ខូចខាត ដោយសារសង្គ្រាម ឬទំនាស់ដោយអាវុធ ការផ្លាស់ប្តូររបបនយោបាយ ការប្រកាសភាពអាសន្នរបស់ប្រទេស ឬការបះបោរ ដែលកើតឡើងក្នុងទឹកដីនៃភាគីកិច្ចសន្យាមួយទៀត ត្រូវបានទទួលនូវប្រព្រឹត្តិកម្ម ដោយអនុលោមទៅតាមមាត្រា ៤ នៃកិច្ចព្រមព្រៀងនេះ ដូចជា បដិទាន សំណង ប្រាក់បំពេញខាត ឬដំណោះស្រាយដទៃទៀត ។

## មាត្រាទី ៧

## គោលការណ៍នៃការផ្ទេរសិទ្ធិបន្ត

ប្រសិនបើភាគីកិច្ចសន្យាមួយបានផ្តល់នូវការធានាផ្នែកហិរញ្ញវត្ថុ ប្រឆាំងទល់នឹងការខូចខាតមិនមែនពាណិជ្ជកម្ម លើការវិនិយោគដែលធ្វើឡើងដោយវិនិយោគិនរបស់ខ្លួននៅក្នុងទឹកដីនៃភាគីកិច្ចសន្យាមួយទៀត ភាគីក្រោយនេះត្រូវទទួលស្គាល់សិទ្ធិរបស់ភាគីដំបូង ដោយផ្អែកលើគោលការណ៍នៃការផ្ទេរសិទ្ធិបន្តរបស់វិនិយោគិន នៅពេលដែលការទូទាត់ត្រូវបានអនុវត្តឡើង តាមការធានារបស់ភាគីកិច្ចសន្យាដំបូង ។

## មាត្រាទី ៨

## វិវាទរវាងភាគីកិច្ចសន្យានិងវិនិយោគិន នៃភាគីកិច្ចសន្យាមួយទៀត

១- ក្នុងទស្សនៈដោះស្រាយវិវាទប្រកបដោយការយោគយល់ រវាងភាគីកិច្ចសន្យានិងវិនិយោគិននៃភាគីកិច្ចសន្យាមួយទៀត ការពិគ្រោះយោបល់នឹងត្រូវបង្កើតឡើងរវាងភាគីពាក់ព័ន្ធ ។

២- ប្រសិនបើការពិគ្រោះយោបល់ទាំងនេះមិនផ្តល់លទ្ធផលជាដំណោះស្រាយទេ ក្នុងកំឡុងប្រាំមួយខែចាប់ពីថ្ងៃស្នើសុំអោយមានការពិគ្រោះយោបល់មក វិនិយោគិននឹងមានសិទ្ធិបញ្ជូនវិវាទនេះជូនទៅ÷

(ក) - មជ្ឈមណ្ឌលអន្តរជាតិសំរាប់ដោះស្រាយវិវាទវិនិយោគ ដែលបានបង្កើតឡើងដោយអនុសញ្ញាស្តីពីដំណោះស្រាយវិវាទវិនិយោគរវាងរដ្ឋនានា និងជនជាតិនៃរដ្ឋដទៃ ដែលបានត្រូវបានចុះហត្ថលេខានៅទីក្រុងវ៉ាស៊ីនតោន នៅថ្ងៃទី ១៨ មិនា ឆ្នាំ ១៩៦៥ បន្ទាប់ពីព្រះរាជាណាចក្រកម្ពុជាក្លាយជាភាគីមួយនៃអនុសញ្ញានោះ ឬក៏

(ខ)- អាជ្ញាកណ្តាលនៃសាលាជំរះក្តី «អាដហុក» ដែលបង្កើតឡើងដោយច្បាប់អាជ្ញាកណ្តាលរបស់គណៈកម្មការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ ប្រសិនបើមានការឯកភាពពីភាគីវិវាទទាំងសងខាង ។ ភាគីវិវាទទាំងសងខាងអាចឯកភាពគ្នាអោយមានអាជ្ញាកណ្តាលតែម្នាក់ផងដែរ ។

៣- ក្នុងរយៈពេលនៃដំណោះស្រាយ ឬការអនុវត្តន៍សេចក្តីសំរេចរបស់អាជ្ញាកណ្តាលនៃសាលាជំរះក្តី ភាគីកិច្ចសន្យាដែលជាភាគីវិវាទពុំអាចលើកបញ្ហាថា វិនិយោគិនបានទទួលនូវសំណងសំរាប់ការខូចខាតមួយភាគ ឬទាំងស្រុង អាស្រ័យដោយកិច្ចសន្យាធានារ៉ាប់រងណាមួយឡើយ ។

៤- គ្មានភាគីកិច្ចសន្យាណាមួយអាចស្វែងរកដំណោះស្រាយតាមរយៈផ្លូវទូត ចំពោះវិវាទណាដែលបានស្នើទៅអាជ្ញាកណ្តាលអន្តរជាតិឡើយ លុះត្រាណាតែមានភាគីកិច្ចសន្យាមួយទៀតពុំបានអនុវត្តតាមការសំរេចនៃអាជ្ញាកណ្តាលនៃសាលាជំរះក្តី ។

## មាត្រា ៩
## វិវាទរវាងភាគីកិច្ចសន្យា

១- វិវាទរវាងភាគីកិច្ចសន្យាដែលពាក់ព័ន្ធទៅនឹងបំណកស្រាយ ឬការអនុវត្តន៍កិច្ចព្រមព្រៀងនេះ នឹងត្រូវដោះស្រាយតាមរយៈផ្លូវទូត ។

២- ប្រសិនបើភាគីកិច្ចសន្យាទាំងពីរមិនអាចព្រមព្រៀងគ្នាបាន ក្នុងរយៈពេលប្រាំមួយខែបន្ទាប់ពីវិវាទនេះត្រូវបានចាប់ផ្តើម តាមសំណើរបស់ភាគីកិច្ចសន្យាណាមួយ វិវាទនេះត្រូវបញ្ជូនទៅកាន់អាជ្ញាកណ្តាលនៃសាលាជំរះក្តី ដែលមានសមាជិកបីរូប ។ ភាគីកិច្ចសន្យានីមួយៗនឹងតែងតាំងអាជ្ញាកណ្តាលមួយរូប ហើយអាជ្ញាកណ្តាលទាំងពីររូបនេះនឹងតែងតាំងប្រធានមួយរូប ដែលជាជនជាតិនៃប្រទេសទីបី ។

៣- ប្រសិនបើភាគីកិច្ចសន្យាណាមួយ ពុំបានតែងតាំងអាជ្ញាកណ្តាលរបស់ខ្លួន ហើយមិនបានធ្វើតាមការស្នើសុំតែងតាំងអាជ្ញាកណ្តាលរបស់ភាគីកិច្ចសន្យាមួយទៀតក្នុងរយៈពេល២ខែ តាមសំណើរបស់ភាគីកិច្ចសន្យាក្រោយនេះ ប្រធានតុលាការយុត្តិធម៌អន្តរជាតិនឹងធ្វើការតែងតាំងអាជ្ញាកណ្តាលនេះ ។

៤- ប្រសិនបើអាជ្ញាកណ្តាលទាំងពីរមិនព្រមព្រៀងគ្នាក្នុងការជ្រើសតាំងប្រធាន ក្នុងរយៈពេលពីរខែ បន្ទាប់ពីពេលដែលខ្លួនត្រូវបានតែងតាំង តាមសំណើរបស់ភាគីកិច្ចសន្យាណាមួយ ប្រធានអាជ្ញាកណ្តាលនឹងត្រូវបានតែងតាំងឡើងដោយប្រធានតុលាការយុត្តិធម៌អន្តរជាតិ ។

៥- ក្នុងករណីដែលមានចែងក្នុងកថាខណ្ឌ (៣) និង (៤) នៃមាត្រានេះ ប្រសិនបើប្រធានតុលាការយុត្តិធម៌អន្តរជាតិត្រូវបានហាមឃាត់ក្នុងការអនុវត្តន៍តួនាទីរបស់ខ្លួន ឬជាជនជាតិនៃភាគីកិច្ចសន្យាណាមួយ ការតែងតាំងនោះនឹងត្រូវធ្វើឡើងដោយអនុប្រធាន ហើយប្រសិនបើអនុប្រធានត្រូវបានហាមឃាត់ក្នុងការអនុវត្តន៍តួនាទីរបស់ខ្លួន ឬជាជនជាតិនៃភាគីកិច្ចសន្យាណាមួយ ការតែងតាំងនោះនឹងត្រូវធ្វើឡើងដោយចៅក្រមនៃតុលាការដែលមានបទពិសោធន៍ខ្ពស់ជាងគេ ហើយដែលមិនមែនជាជនជាតិរបស់ភាគីកិច្ចសន្យាណាមួយទេ។

៦- សាលាជំរះក្តីជាអ្នកកំណត់នីតិវិធីរបស់ខ្លួន លើកលែងតែមានបទបញ្ញត្តិផ្សេងទៀតដែលភាគីកិច្ចសន្យាទាំងពីរបានព្រមព្រៀងគ្នា ។

៧- សេចក្តីសំរេចរបស់សាលាជំរះក្តីជាការសំរេចចុងក្រោយ ហើយមានប្រសិទ្ធិភាពយ៉ាងពេញទំហឹងនៅលើភាគីកិច្ចសន្យាទាំងពីរ ។

## មាត្រា១០

## ការប្តេជ្ញាផ្សេងទៀត

១- ប្រសិនបើបទបញ្ញត្តិក្នុងនីតិកម្មរបស់ភាគីកិច្ចសន្យាណាមួយ ឬវិធាននៃច្បាប់អន្តរជាតិ ដែលផ្តល់ឲ្យការវិនិយោគរបស់វិនិយោគិននៃភាគីកិច្ចសន្យាមួយទៀត បានផ្តល់ប្រព្រឹត្តិកម្មអនុគ្រោះជាងប្រព្រឹត្តិកម្មដែលមានចែងក្នុងកិច្ចសន្យានេះ បទបញ្ញត្តិនោះនឹងមានវិសាលភាពទៅលើកិច្ចព្រមព្រៀងនេះ ។

២- ភាគីកិច្ចសន្យានីមួយៗនឹងគោរពនូវកាតព្វកិច្ចណាមួយ ដែលខ្លួនបានទទួលស្គាល់ចំពោះការវិនិយោគក្នុងទឹកដីរបស់ខ្លួនដោយវិនិយោគិននៃភាគីកិច្ចសន្យាមួយទៀត ។

## មាត្រាទី ១១

## អវសានបញ្ញត្តិ

១- កិច្ចព្រមព្រៀងនេះនឹងចូលជាធរមាន នៅថ្ងៃដែលរដ្ឋាភិបាលនៃប្រទេសទាំងពីរបានជូនដំណឹងថាខ្លួនបានបំពេញនូវនីតិវិធីសំរាប់ការចូលជាធរមាននៃកិច្ចព្រមព្រៀងអន្តរជាតិ ហើយកិច្ចព្រមព្រៀងនឹងមានសុពលភាពយ៉ាងពេញលេញសំរាប់រយៈពេលដប់ឆ្នាំ ។ ដរាបណាគ្មានការបញ្ជាក់ជាលាយល័ក្ខអក្សរស្តីពីការបញ្ចប់កិច្ចព្រមព្រៀងនេះ ក្នុងរយៈពេលប្រាំមួយខែមុនពេលផុតកំណត់នៃកិច្ចព្រមព្រៀងទេ កិច្ចព្រមព្រៀងនេះនឹងត្រូវនៅមានប្រសិទ្ធិភាពបន្តដោយរក្សាខ្លឹមសារនៅដដែល សំរាប់រយៈពេលពីរឆ្នាំ និងជាបន្តបន្ទាប់ទៀត ។

២- ក្នុងករណីមានការជូនដំណឹងជាផ្លូវការដើម្បីបញ្ចប់កិច្ចព្រមព្រៀងនេះ ពីសំណាក់ភាគីកិច្ចសន្យាណាមួយ បទបញ្ញត្តិក្នុងមាត្រាទី ១ រហូតដល់ទី ១០ នឹងត្រូវនៅមានប្រសិទ្ធិភាពសំរាប់រយៈពេលដប់ឆ្នាំ សំរាប់ការវិនិយោគទាំងឡាយដែលបានបង្កើតឡើង មុនពេលមានការផ្តល់ដំណឹងនេះជាផ្លូវការ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ១៩៩៦ ជាភាសាខ្មែរ បារាំង និងអង់គ្លេស អត្ថបទទាំងអស់មានតម្លៃស្មើគ្នាតាមផ្លូវច្បាប់ ។ ក្នុងករណីមានការបកស្រាយខុសគ្នា អត្ថបទជាភាសាអង់គ្លេសនឹងត្រូវយកជាគោល ។

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

ក្រុមប្រឹក្សាសហពន្ធ័ស្វីស